# សេចក្ដីប្រកាសវិសាខបូជា

បពិត្រទេព្តាគ្រប់ទិសទសសោឡស្ថាន បពិត្រទេវតាដែលថែរក្សាព្រះពុទ្ធបដិមា និងថែរក្សាទីអារាម ទាំងអស់, ថ្ងៃនេះមានព្រះពុទ្ធបដិមាជាប្រធាន ព្រះធម៌ជាសព៌ជ្ញញាណ ព្រះសង្ឃជាអធិបតី នាងគង្ហីង ព្រះធរណីជាកសិណសាក្សី, ថ្ងៃនេះព្រះសង្ឃនិងពួកពុទ្ធបរិស័ទនៃ វត្តធម្មរារាម បាននាំគ្នាប្រារព្ធ រៀបចំធ្វើនូវពិធីបុណ្យវិសាខបូជា ដើម្បីគោរពរំឭកដល់ហេតុដ៏ អស្ចារ្យនៃព្រះសព្វញ្ញូបរមគ្រូជាម្ចាស់នៃយើង ៣យ៉ាងគឺៈ

១-ទ្រង់ប្រសូត, ២-ទ្រង់ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ, ៣-ទ្រង់បរិនិព្វាន។

ទេវតាក្នុងចក្រវាឡទាំងឡាយ ព្រះនាង**ធង្សទេវី** ដែលចុះមកថែរក្សាមនុស្សលោកយើងក្នុងឆ្នាំ **ម្សាញ់ បញ្ចស័ក**នេះសូម អញ្ជើញមកប្រជុំគ្នាក្នុងទីនេះ ចូរស្ដាប់នូវព្រះសទ្ធម្ម ជាធម៌អាច ឱ្យនូវស្ថានសួគ៌និង ព្រះនិព្វាន ( របស់ព្រះភគវា ព្រះឈ្នះមារ ) ជាស្ដេចនៃអ្នកប្រាជ្ញ។

ព្រះពុទ្ធជាទីពឹងនៃខ្ញុំ, ព្រះធម៌ជាទីពឹងនៃខ្ញុំ, ព្រះសង្ឃជាទីពឹងនៃខ្ញុំ។ ព្រះមហាសត្ត សក្យមុនីទ្រង់ព្រះ នាម **សិទ្ធត្ថៈ គោតម** ទ្រង់ប្រសូតក្នុងទីណា ទីនោះឈ្មោះ **លុម្ពិនី** ជាសំវេជនីយដ្ឋានទី១។

ព្រះមហាសត្ត **សិទ្ធត្ថៈ** ទ្រង់បានត្រាស់ដឹងក្នុងទីណា ទីនោះឈ្មោះ **ពុទ្ធគយា** ជាទីផុសឡើងនៃពោធិ បល្ល័ង្ក ដែលព្រះសព្វញ្ញុពុទ្ធគ្រប់ព្រះអង្គទ្រង់ចាប់អារម្មណ៍ ជាសំវេជនីយដ្ឋានទី២។

ព្រះធម្មចក្កប្បវត្តនសូត្រ ( ជាបឋមទេសនា ) ដែលព្រះសម្ពុទ្ធទ្រង់ប្រកាសហើយក្នុងទីណា ទីនោះ ឈ្មោះ **ឥសិបតនៈមិគទាយវ័ន** ជាសំវេជនីយដ្ឋានទី៣។

ព្រះសម្ពុទ្ធជាអ្នកប្រាជ្ញឆ្នើមរបស់សក្យទាំងឡាយ ទ្រង់បរិនិព្វានហើយក្នុងទីណា ទីនោះឈ្មោះ **កុសិនារា** ជាសំវេជនីយដ្ឋានទី៤។

បពិត្រព្រះករុណាគ្រប់ព្រះអង្គ និងពុទ្ធបរិស័ទទាំងឡាយ អ្នកឯណាមួយ ជាអ្នកប្រតិបត្តិនូវធម៌ ដ៏សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយត្រឹមត្រូវ ជាអ្នកប្រព្រឹត្តតាមធម៌ជាប្រក្រតី អ្នកនោះឈ្មោះ ថាធ្វើ **សក្ការៈ** ធ្វើសេចក្ដីគោរពរាប់អានបូជានូវព្រះ**តថាគត** ដោយបដិបត្តិបូជា ជាបូជាដ៏ឧត្តម។ កិរិយា

មិនធ្វើនូវបាបទាំងពួង កិរិយាបំពេញនូវកុសលទាំងពួង កិរិយាអប់រំធ្វើចិត្តរបស់ខ្លួនឱ្យផូរផង់ ទាំងនេះជាពាក្យប្រៀនប្រដៅ នៃព្រះពុទ្ធទាំងឡាយ ។

កិរិយាបានត្រាស់ដឹងនៃព្រះពុទ្ធទាំងឡាយ នាំមកនូវសេចក្តីសុខ កិរិយាសំដែងនូវធម៌របស់សប្បុរស នាំមកនូវសេចក្តីសុខ សេចក្តីព្រមព្រៀងគ្នារបស់សង្ឃឬពួកក្រុម នាំមកនូវសេចក្តីសុខ សេចក្តីព្យាយាមរបស់អ្នកដែលព្រមព្រៀងគ្នាទាំងឡាយ នាំមកនូវសេចក្តីសុខ ។

បុគ្គលឯណាបានស្តាប់នូវព្រះសទ្ធម្មរបស់ព្រះសាស្តា(ដែលរាប់បញ្ចូល) ក្នុងពាក្យប្រៀនប្រដៅនៃព្រះវិជិតមារទាំងពួង បុគ្គលនោះរមែងមិនទៅកាន់ទុគ្គតិអស់សែនកប្ប ។

ព្រះវិជិតមារ ព្រះអង្គទ្រង់យាងចុះមកអាស្រ័យនៅក្នុងព្រះគភ៌ (នៃព្រះវរមាតា) ក្នុងឆ្នាំរកា, ទ្រង់ប្រសូតចាកគភ៌ក្នុងឆ្នាំ**ច** ទ្រង់សោយរាជសម្បត្តិក្នុងឆ្នាំឆ្លូវ, ទ្រង់ព្រះផ្នួសក្នុងឆ្នាំថោះ ។

ទ្រង់ត្រាស់ដឹងជាព្រះសព្វញ្ញុពុទ្ធក្នុងឆ្នាំរកា ទ្រង់សំដែងនូវព្រះធម្មចក្កក្នុងឆ្នាំនោះ ទ្រង់យាងចូលកាន់ព្រះនិព្វានក្នុងឆ្នាំម្សាញ់, ព្រះពុទ្ធសាសនានឹងគ្រប់៥០០០គត់ក្នុងឆ្នាំជូត ។

ទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា ) ក្នុងថ្ងៃព្រហស្បតិ៍, ប្រសូតក្នុងថ្ងៃសុក្រ, បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពុធ, បរិនិព្វានក្នុងថ្ងៃអង្គារ ។

ព្រះអង្គទ្រង់យាងចុះកាន់ព្រះគភ៌ (នៃព្រះវរមាតា) ក្នុងថ្ងៃពេញបូណ៌មីខែអាសាឍ, ប្រសូតក្នុងថ្ងៃពេញបូណ៌មីខែវិសាខ, បានត្រាស់ជាព្រះសម្ពុទ្ធក្នុងថ្ងៃពេញបូណ៌មីខែវិសាខ, បរិនិព្វានក្នុងថ្ងៃពេញបូណ៌មីខែវិសាខ។

ម្នាលអានន្ទ សភាវៈឯណា គឺព្រះធម៌ក្តី ព្រះវិន័យក្តី ដែលតថាគតបានសំដែងហើយ បានបញ្ញត្តហើយដល់អ្នកទាំងឡាយ ។ សភាវៈគឺព្រះធម៌និងព្រះវិន័យនោះ លុះអំណើះតអំពីតថាគតទៅហើយ នឹងបានជាគ្រូប្រៀនប្រដៅនូវអ្នកទាំងឡាយ ។

ម្នាលអានន្ទ បុគ្គលឯណាមួយ គឺភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាអ្នកប្រតិបត្តិនូវធម៌វិន័យតាមសមគួរដល់ធម៌វិន័យ ជាអ្នកប្រតិបត្តិដោយសេចក្តីគោរពកោតក្រែងដល់ធម៌វិន័យ ប្រព្រឹត្តតាម

ធម៌វិន័យជាប្រក្រតី ។

បុគ្គលទាំងអស់នោះ បានឈ្មោះថាធ្វើ**សក្ការៈ**នឹង**តថាគត** ធ្វើនូវសេចក្តីគោរព**តថាគត** រាប់អាននូវ**តថាគត** បូជានូវ**តថាគត** ដោយបតិបត្តិបូជា ជាបូជាយ៉ាងក្រៃលែង ។

ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ**តថាគត**នឹងផ្តាំនូវអ្នកទាំងឡាយឱ្យបានដឹងគ្រប់គ្នា ៃ ន !ភិក្ខុទាំងឡាយ សង្ខារទាំងឡាយ មានកិរិយាអស់ទៅនិងសាបសូន្យទៅជាធម្មតា ។ អ្នករាល់គ្នាចូរញុំាងប្រយោជន៏ឱ្យដល់ព្រមដោយអប្បមាទៈ គឺការមិនបណ្តែតបណ្តោយក្នុងធម៌វិន័យ ពាក្យប្រៀនប្រដៅមានប្រមាណ ប៉ុណ្ណេះជាដើមនេះ ឈ្មោះថាបច្ឆិមពុទ្ធវចនៈ ជាពាក្យផ្តាំពៅបំផុតរបស់ព្រះពុទ្ធជាម្ចាស់នៃយើង ។

ដោយសេចក្តីគោរពរំឭកនូវពុទ្ធឱវាទនៃព្រះសព្វញ្ញូបរមគ្រូ ជាម្ចាស់នៃយើងនាឱកាសដ៏ថ្លៃថ្លានេះ សូមឱ្យព្រះសង្ឃគ្រប់ព្រះអង្គ និងយើងខ្ញុំទាំងអស់គ្នាបានដល់នូវសុភមង្គលគ្រប់ប្រការ កុំបីមានទុក្ខ កុំបីមានពៀរ កុំបីមានក្តៅក្រហាយ កុំបីមានក្តីលំបាក ឱ្យបានសុខរក្សាខ្លួនតទៅ ។

ពួកសត្វទាំងអស់ ពួកប្រាណទាំងអស់ ពួកភូតទាំងអស់ ពួកបុគ្គលទាំងអស់ ពួកសត្វដែលរាប់បញ្ចូលថាមានអត្តភាពទាំងអស់ ពួកបុរសទាំងអស់ ពួកស្ត្រីទាំងអស់ ពួកព្រះអរិយទាំងអស់ ពួកបុថុជ្ជនទាំងអស់ ពួកទេវតាទាំងអស់ ពួកមនុស្សទាំងអស់ ពួកវិនិបាតទាំងអស់ សូមកុំឱ្យមានពៀរនឹងគ្នា កុំបៀតបៀនគ្នា កុំមានទុក្ខ សូមរក្សានូវខ្លួនឱ្យជាសុខចុះ។

មួយទៀត សត្វទាំងឡាយទាំងពួង ដែលកំពុងដល់ហើយនូវសេចក្តីទុក្ខ សូមឱ្យជាសត្វបាត់សេចក្តីទុក្ខទៅ, ដែលកំពុងដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ, ដែលកំពុងដល់ហើយនូវសេចក្តីសោក សូមឱ្យជាសត្វបាត់សេចក្តីសោកទៅហោង ។

**បន្ទាប់អំពីនេះ** វេរគ្រឿងសក្ការៈ នមស្សការសមាទានសីល ស្តាប់ព្រះបរិត្ត ស្តាប់ធម៌ទេសនា រួចនាំគ្នាសូត្រធម៌បទផ្សេងៗ ទៅតាមពេលវេលាដែលអាចធ្វើទៅបាន ។ សេចក្តីនេះ ថ្លែងនៅថ្ងៃព្រហស្បតិ៍ ១៥ កើត ខែវិសាខ ឆ្នាំថោះ ព.ស. ២៥៤២ ត្រូវនិងថ្ងៃទី ២៩ ខែមេសា ឆ្នាំ១៩៩៩ នៅក្នុងឧបដ្ឋានសាលា **វត្តធម្មារាម** ។

**ទ៊ាន់ អ៊ុង**

ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ទ៊ាន់ អ៊ុង** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣

វាយចម្លងដាក់គេហទំព័រវត្ត ដោយខ្ញុំព្រះករុណាខ្ញុំបាទ **អ៊ុន លី** ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២

វត្តធម្មារាម